Your Information - **It's Private** CAMBODIAN

State Government Victoria Department of Human Services

# ព័ត៌មានរបស់លោកអ្នក គឺជារឿងឯកជន

## តើមានហេតុការណ៍អ្វីកើតឡើងទៅចំពោះពត៌មានអំពីលោកអ្នក ក្នុងកាលលោកអ្នកជាអ្នកប្រើប្រាស់កិច្ចបំរើនេះ?

### តើយើងជានរណា?

យើងជាកិច្ចបំរើថែទាំសុខភាព និងសហគមន៍មួយក្នុងចំណោមកិច្ចបំរើជាច្រើនទៀត នៅក្នុងតំបន់របស់លោកអ្នក យើងទាំងអស់ធ្វើការរួមគ្នាជាដៃគូ ដើម្បីបំពេញទៅលើសេចក្តីត្រូវការផ្នែកសុខភាពរបស់លោកអ្នក។

### តើពត៌មានអ្វីខ្លះដែលយើងប្រមូលទុកអំពីលោកអ្នក?

យើងរក្សាទុកឈ្មោះ និងពត៌មានទាក់ទងរបស់លោកអ្នក នៅលើសំណុំរឿងប្រើប្រាស់របស់លោកអ្នក។ ពត៌មានដ៏ទៃទៀតដូចជាគំរោងថែទាំរបស់លោកអ្នក និងពត៌មានអំពីសុខភាពរបស់លោកអ្នកត្រូវបានកត់ទុករៀងរាល់ពេលដែលលោកអ្នកមកជួបយើង។

### ហេតុអ្វីបានជាយើងប្រមូលទុកនូវពត៌មានរបស់លោកអ្នក?

ពត៌មានដែលយើងប្រមូលយក ជួយយើងរក្សាទុកមិនឲ្យបាត់នូវពត៌មានអំពីសេចក្តីត្រូវការរបស់លោកអ្នក ដើម្បីឲ្យយើងថែទាំលោកអ្នក នៅក្នុងលំនាំដ៏ល្អបំផុត។ យើងក៏ប្រើពត៌មាននេះដើម្បីចាត់ចែង និងដើម្បីធ្វើគំរោងកិច្ចបំរើនេះឲ្យបានល្អប្រសើរជាង។

### តើមាននរណាទៀតដែលមើលពត៌មានរបស់លោកអ្នក?

ពត៌មានរបស់លោកអ្នកអាចមើលបានតែបុគ្គលិកដែលមានវិជ្ជាជីវៈ នៅក្នុងកិច្ចបំរើនេះ ដែលជាប់ទាក់ទិននឹងការមើលថែទាំលោកអ្នកប៉ុណ្ណោះ។ ប្រសិនបើពុំដូច្នោះទេ យើងបញ្ចេញពត៌មានអំពីលោកអ្នក ប្រសិនបើលោកអ្នកយល់ព្រម ឬមានការតម្រូវពីច្បាប់តែប៉ុណ្ណោះ ដូចជាពេលមានភាពអាសន្នដែលគំរាមកំហែងដល់ជីវិត។

### តើលោកអ្នកមានសិទ្ធិយ៉ាងណាខ្លះចំពោះអ្វីដែលកើតមានឡើងដល់ពត៌មានរបស់លោកអ្នក?

លោកអ្នកមានសិទ្ធិនិយាយ ចំពោះអ្វីដែលកើតមានឡើងដល់ពត៌មានរបស់លោកអ្នក។ យើងពឹងផ្អែកទៅលើពត៌មានដែលលោកអ្នកផ្តល់មកឲ្យយើង ដើម្បីជួយយើងផ្តល់ការថែទាំដ៏សមរម្យដល់លោកអ្នក។ ប្រសិនបើលោកអ្នកសំរេចមិនឲ្យចែករំលែកនូវពត៌មានរបស់លោកអ្នកខ្លះ ឬដាក់កំរិតឲ្យប្រើសំណុំរឿងប្រើប្រាស់របស់លោកអ្នក នេះគឺជាសិទ្ធិរបស់លោកអ្នក ក៏ប៉ុន្តែវាអាចប៉ះពាល់ទៅលើសមត្ថភាពរបស់យើង ដើម្បីផ្តល់ជូនលោកអ្នកនូវកិច្ចបំរើល្អបំផុតដែលអាចធ្វើទៅបាន។ សូមជម្រាបប្រាប់យើង ប្រសិនបើលោកអ្នកមានបំណងចង់ផ្លាស់ប្តូរ ឬលុបចោលនូវការយល់ព្រមរបស់លោកអ្នក។

### តើពត៌មានរបស់លោកអ្នកនឹងត្រូវបានការពារដោយរបៀបណា?

យើងបានប្តេជ្ញាចិត្តដើម្បីការពារភាពសម្ងាត់ នៃសំណុំរឿងរបស់លោកអ្នក។ ភាពឯកជននៃពត៌មានរបស់លោកអ្នក ក៏ត្រូវបានការពារពីច្បាប់ផងដែរ។ យើងចាត់ទុកពត៌មានរបស់លោកអ្នកយ៉ាងសម្ងាត់ជាទីបំផុត ហើយដំកល់ទុកដោយសុវត្ថិភាព។

### តើលោកអ្នកអាចប្រើប្រាស់ពត៌មានរបស់លោកអ្នកបានឬទេ?

ជាប្រាកដណាស់ លោកអ្នកមានសិទ្ធិសុំប្រើប្រាស់ពត៌មានរបស់លោកអ្នកបាន ហើយអាចស្នើសុំឲ្យគេកែតម្រូវ ប្រសិនបើចាំបាច់។

### តើមានសំណួរណាទៀតឬទេ?

សូមនិយាយទៅកាន់បុគ្គលិករបស់យើងណាម្នាក់ ប្រសិនបើលោកអ្នកមានសំណួរណាមួយ ឬមានបំណងចង់តវ៉ាអំពីអ្វីដែលកើតមានដល់ ពត៌មានរបស់លោកអ្នក ក្នុងពេលលោកអ្នកជាអ្នកប្រើប្រាស់កិច្ចបំរើរបស់យើង ឬប្រសិនបើលោកអ្នកមានបំណងចង់ប្រើសំណុំរឿងរបស់ លោកអ្នក។